# ធ្វើការរួមគ្នាដើម្បីការព្យាបាល និងស្តារនិតិសម្បទាអ្នកញៀនគ្រឿងញៀន

# " មជ្ឈមណ្ឌលគំរូ "

អ្នកចងក្រង: លោក.ប៉ែន រដ្ឋា, លោក Frederick CURTIS,
អ្នកស្រី. Caroline FRANCIS

អង្គភាព: អង្គការសុខភាពគ្រួសារអន្តរជាតិ / កម្ពុជា

USAID
ជំនួយពីពលរដ្ឋអាមេរិក

ប្រសិទ្ធ | PRASIT

# សេចក្ដីផ្ដើម

✓ ការប្រើប្រាស់គ្រឿងញៀន និងឥរិយាបថនៃការប្រព្រឹត្តដោយភាពប្រឈមមុខជាការគំរាមកំហែងមួយ ធ្វើឱ្យបញ្ហាស់ន្ទរការធ្លាក់ចុះអត្រាឆ្លងជំងឺអេដស៍

✓ នៅឆ្នាំ២០០៦ រដ្ឋាភិបាលកម្ពុជាបានធ្វើការអំពាវនាវបង្កើតមជ្ឈមណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀន គ្រប់ខេត្ត-ក្រុង ទាំងអស់

✓ សព្វថ្ងៃនេះមានមជ្ឈមណ្ឌលព្យាបាលចំនួន ១០កន្លែង ក្នុង៧ ខេត្ត-ក្រុង បាននឹងកំពុងដំណើរការព្យាបាលអ្នកញៀនគ្រឿងញៀន

USAID ជំនួយពីពលរដ្ឋអាមេរិក

ប្រសិទ្ធ | PRASIT

- នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៧ មានអ្នកញៀនគ្រឿងញៀនសរុបចំនួន ២៨០៩ នាក់ បានចូលមកសំរាកព្យាបាលក្នុងមជ្ឈមណ្ឌល
- សេវាសុខភាពចំបងៗ និងសេវាបញ្ជូន មិនទាន់ឆ្លើយតបតាមតំរូវការនៅឡើយទេ
- គ្មានគំរូណាមួយត្រូវបានយកមកអនុវត្ត ដើម្បីទទួលបានភាពជោគជ័យនោះទេ
- ភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលត្រូវការជាចាំបាច់សំរាប់ផ្តល់សេចក្តីត្រូវការដល់អ្នកប្រើបាស់គ្រឿងញៀន

USAID ជំនួយពីពលរដ្ឋអាមេរិក

ប្រសិទ្ធ | PRASIT

# សេចក្តីអធិប្បាយ

✓ នៅខែវិច្ឆិកា ឆ្នាំ២០០៧: អង្គការសុខភាពគ្រួសារអន្តរជាតិ បានសហការជាមួយ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចុះធ្វើការវាយតំលៃស្ថានភាពមជ្ឈមណ្ឌលព្យាបាល ចំនួន ៤ កន្លែង

✓ លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសដើម្បីធ្វើការវាយតំលៃនេះ គឺដោយមណ្ឌលទាំងអស់នោះមាន ទំនាក់ទំនងជាមួយរដ្ឋាភិបាល,មានចំនួនអតិថិជនច្រើន និងសមត្ថភាពយល់ដឹងពីការកែទំរង់ ឬការផ្លាស់ប្តូរ

USAID ជំនួយពីពលរដ្ឋអាមេរិក

ប្រសិទ្ធ | PRASIT

- មជ្ឈមណ្ឌលឱកាសខ្ញុំ ដែលគ្រប់គ្រងដោយសាលាក្រុងភ្នំពេញ ត្រូវបានជ្រើសរើសអនុវត្តកម្មវិធីសាកល្បងផ្តល់នូវជំនួយបច្ចេកទេស គឺអាស្រ័យដោយទីតាំងភូមិសាស្ត្រ និងចំនួនអ្នកញៀនគ្រឿងញៀន មកសំរាកព្យាបាលមានចំនួនច្រើនជាងគេ

- នៅខែធ្នូ ឆ្នាំ២០០៧:អង្គការសុខភាពគ្រួសារអន្តរជាតិ និងអង្គការសុខភាពពិភពលោក បានធ្វើការវាយតំលៃតំរូវការមជ្ឈមណ្ឌលឱកាសខ្ញុំ អនុសាសន៏ជំនួយបច្ចេកទេសត្រូវបានបង្ហាញឱ្យឃើញ

- ជំនួយបច្ចេកទេសទាំងនោះរួមមាន ការសំរបសំរួលឱ្យមានវគ្គបណ្តុះបណ្តាល សិក្ខាសាលាស្តីអំពី ចំណេះដឹងការបង្ការការព្យាបាលមេរោគអេដស៍/របេង/កាមរោគ/រលាកថ្លើម/ការញៀន ការបង្កើនសមត្ថភាពក្នុងស្ថាប័ន រួមមាន ការគ្រប់គ្រងករណីនីមួយៗ ការផ្តល់សេវាចិត្តសង្គម និង ការតាមដាន-វាយតំលៃ

- ✓ រៀបចំការប្រជុំជាមួយមជ្ឈមណ្ឌលឱកាសខ្ញុំ និងសាលាក្រុងភ្នំពេញ ដើម្បីពិភាក្សាអំពីកញ្ចប់ជំនួយបច្ចេកទេស សំរាប់កម្មវិធីសាកល្បង

- ✓ ការប្រជុំជាមួយភាគីពាក់ព័ន្ធ ដើម្បីពិភាក្សាពីកិច្ចសហប្រតិបត្តិការណ៍ រកយុទ្ធសាស្រ្តថ្មីៗបន្ថែម និង បង្ការការធ្វើការជាន់គ្នា ដែលអាចកើតមានឡើងនាពេលអនាគត

- ✓ អង្គការសុខភាពគ្រួសារអន្តរជាតិ និងមជ្ឈមណ្ឌលឱកាសខ្ញុំ បានឯកភាពគ្នាក្នុងភាពជាដៃគូ ដើម្បីប្រែក្លាយមជ្ឈមណ្ឌលនេះទៅជាមជ្ឈមណ្ឌលគំរូមួយ សំរាប់ព្យាបាល ស្តារនិតិសម្បទាអ្នកញៀនគ្រឿងញៀន

USAID
ជំនួយពីប្រជាជនអាមេរិក

ប្រសិទ្ធ | PRASIT

✓ នៅពេលដែលកញ្ចប់ជំនួយបច្ចេកទេស ត្រូវបានអនុវត្ត ហើយរីកចំរើននោះ យើងអាចធ្វើការពង្រីកទៅដល់មជ្ឈមណ្ឌលដទៃផ្សេងទៀត

# មេរៀន និងបទពិសោធន៍

✓ស្ថានភាព និងការវាយតម្លៃតំរូវការ មានលក្ខណះច្បាស់លាស់ នៅពេលដែលមានពេលវេលាគ្រប់គ្រាន់ចុះពិនិត្យដល់កន្លែង និងសំភាសន៍ជាមួយគណៈគ្រប់គ្រង បុគ្គលិកព្យាបាល និងអ្នកញៀនគ្រឿងញៀន

USAID
ជំនួយពីពលរដ្ឋអាមេរិក

ប្រសិទ្ធ | PRASIT

✓ ការប្រជុំជាច្រើនទៀតជាមួយភាគីពាក់ព័ន្ធចាំបាច់ត្រូវតែមាន ដើម្បីផ្តោតទៅលើការបង្ការ ការធ្វើការជាន់គ្នា ដែលអាចកើតមានឡើងនៅពេលអនាគត

✓ គ្មានអង្គការតែឯកឯងណា ដែលមានជំនាញក្នុងការផ្តល់ជំនួយបច្ចេកទេស អាចធ្វើឱ្យមជ្ឈមណ្ឌលនេះក្លាយជាមជ្ឈមណ្ឌលគំរូសំរាប់ព្យាបាល ស្តារនិតិសម្បទាអ្នកញៀនគ្រឿងញៀនបាននោះទេ ដូចនេះភាពជាដៃគូចាំបាច់ត្រូវតែមាន

USAID ជំនួយពីពលរដ្ឋអាមេរិក

ប្រសិទ្ធ | PRASIT

# ការផ្តល់អនុសាសន៍

- អង្គការសុខភាពគ្រួសារអន្តរជាតិ ត្រូវតែធ្វើការជាមួយស្ថាប័នរដ្ឋាភិបាល ដូចជា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអង្គការសហប្រជាជាតិផ្សេងទៀត ដើម្បីបង្កើត និងអនុម័តទំរង់បែបបទថ្មីៗ និងឯកសារមួយចំនួនទៀត

- ទំរង់បែបបទ និងឯកសារដែលត្រូវបានប្រើប្រាស់នៅមជ្ឈមណ្ឌលឱកាសខ្ញុំ ដែលជាផ្នែកមួយនៃកញ្ចប់ជំនួយបច្ចេកទេស គួរតែត្រូវបានយកទៅប្រើប្រាស់ នៅមណ្ឌលព្យាបាលដទៃផ្សេងទៀត

USAID ជំនួយពីពលរដ្ឋអាមេរិក

ប្រសិទ្ធ | PRASIT

- ✓ អង្គការសុខភាពគ្រួសារអន្តរជាតិ អាចដើរតួដើម្បីបង្កើតឱ្យមានកន្លែងបន្សាបគ្រឿងញៀន គោលនយោបាយនៃការព្យាបាល ស្ដារនិតិសម្បទា, គោលការណ៍ណែនាំ និងនិយាមបែបបទស្តង់ដា នៅក្នុងកំឡុងពេលអនុវត្តកម្មវិធីសាកល្បងនេះ

- ✓ អង្គការសុខភាពគ្រួសារអន្តរជាតិ ត្រូវតែធ្វើការសហការជាមួយអង្គការជាច្រើនទៀត ដូចជា អង្គការ KHANA និង អង្គការ Friend International ដែលពួកគេមានជំនាញច្បាស់លាស់ក្នុងការផ្តល់ជំនួយបច្ចេកទេស ដូចជា ការផ្តល់សេវាក្រោយពេលថែទាំ និង ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ


ORKAS KNHOM CENTER





